គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
ក្រុមការងារគម្រោង LASED

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

# សូមគោរពជូន
# ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**តាមរយៈ:** ឯកឧត្តមអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

**កម្មវត្ថុ** របាយការណ៍ស្តីពីលទ្ធផលការងារប្រចាំខែសីហា ឆ្នាំ២០១៤ របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច(LASED)។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូនឯកឧត្តមប្រធានលេខាធិការដ្ឋានគ.ជ.អ.ប នូវលទ្ធផលនៃការអនុវត្តគម្រោង LASED សម្រេចបានដូចខាងក្រោម៖

## I. **ខឡ្ានភាពគម្រោង**

គម្រោងចុះបញ្ជីដីសរុបបានចំនួន ១០.២៧៣,១៣ហិកតា នៅក្នុងឃុំគោលដៅចំនួន០៧ លើផែនការចំនួន១០.០០០ហិកតា ដែលស្មើនឹង ១០២,៧៣% និងបានបែងចែកជូនប្រជាពលរដ្ឋចំនួន ៣.១៤៨គ្រួសារ លើផែនការចំនួន ៣.០០០គ្រួសារ ស្មើនឹង ១០៥% ដែលក្នុងនោះមានគ្រួសារស្ត្រីជាមេគ្រួសារចំនួន១.០៧០គ្រួសារ។ រហូតមកទល់ពេលបច្ចុប្បន្ន មានប្រជាជនចំនួន១.៩១០គ្រួសារ បានចូលតាំងទីលំនៅលើដីសម្បទាន គឺស្មើនឹង ៦១% នៃចំនួនគ្រួសារសរុបដែលត្រូវបានជ្រើសរើស។ ផ្ទៃដីកសិកម្មដែលបានដាំដុះមានចំនួន ២.៩៩៥ហិកតា ដែលមានដំណាំឈើហូបផ្លែ ដំឡូងមី ស្រូវ និងពោត។ តាមរយៈការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំរបស់គម្រោង បានរកឃើញថា ៨០% នៃគ្រួសារអ្នកទទួលផលបានយកបច្ចេកទេសគ្រប់គ្រងគុណភាពដីមានជាអាទិ៍ បច្ចេកទេសដាំដំណាំចម្រុះគ្នា និងដំណាំឆ្លាស់ បច្ចេកទេសដាំដំណាំដោយប្រើទឹកតិច (Hydroponic ) និងបច្ចេកទេសចិញ្ចឹមសត្វយកទៅអនុវត្តនៅលើដីកសិកម្ម និងដីលំនៅឋាន ដែលគម្រោងបានផ្តល់ឲ្យ។

តាមរយៈការគាំទ្រពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ គម្រោងបានសាងសង់ផ្លូវលំ រៀបចំដីកសិកម្មនិងដីលំនៅឋាន សាងសង់សាលារៀនបានចំនួន៧ខ្នង ស្មើនឹង ៣៥បន្ទប់ សាងសង់ប៉ុស្តិ៍សុខភាពបានចំនួន ៣ខ្នង សាងសង់មណ្ឌលសហគមន៍បានចំនួន ២ខ្នង បោះបង្គោលកំណត់ព្រំដីកសិកម្ម និងដីលំនៅឋាន ជីកស្រះទឹក ចែកសម្ភារសាងសង់ជម្រក និងបង្គន់អនាម័យដល់ប្រជាពលរដ្ឋនៅលើឃុំគោលដៅនៃដីសម្បទានសង្គមកិច្ចនីមួយៗ។

គិតត្រឹមខែសីហា ឆ្នាំ២០១៤ ក្រុមការងារគម្រោងLASED បានអនុវត្តការងារ និងសម្រេចលទ្ធផលបានដូចខាងក្រោម:

មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ : (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

១-ការងារថ្នាក់ជាតិ

- ក្រុមការងារគម្រោងថ្នាក់ជាតិ នៃអគ្គលេខាធិការដ្ឋានដីសម្បទានសង្គមកិច្ចជាតិ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងលេខាធិការដ្ឋាន គ.ជ.អ.ប នៃក្រសួងមហាផ្ទៃ បានសហការគ្នារៀបចំឯកសារគតិយុត្ត និងផែនការសកម្មភាព មួយចំនួន សម្រាប់គាំទ្រការអនុវត្តគម្រោង LASED ដំណាក់កាលទី២ ដូចជា: ១-សៀវភៅណែនាំអំពីនីតិវិធីនៃការអនុវត្តគម្រោង (PIM) សម្រាប់ LASED II ២-នីតិវិធីប្រតិបត្តិសម្រាប់សហគមន៍ (ជាឯកសារប្រតិបត្តិនៅថ្នាក់សហគមន៍ ដោយរាប់បញ្ចូលការងាររដ្ឋបាល ហិរញ្ញវត្ថុ និងលទ្ធកម្ម ដោយគ្រាន់តែជាឯកសារបន្ថែមនៃឧបសម្ព័ន្ធរបស់PIM) ៣-ការរៀបចំក្របខ័ណ្ឌគោលនយោបាយការបោះទីតាំងលំនៅដ្ឋាន និងជនជាតិដើមភាគតិច (ជាឯកសារធានាសុវត្ថិភាព Safeguard សម្រាប់តម្រង់ទិសដល់ការអនុវត្តគម្រោងដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋានក្នុងតំបន់គោលដៅរបស់គម្រោង LASED ទាំង១៣ឃុំ ដោយគិតគូដល់អ្នកទទួលផលដែលគ្មានដី និងខ្វះខាតដីក្នុងឃុំ ព្រមទាំងការចុះបញ្ជីដីដោយមិនធ្វើឱ្យប៉ះពាល់ដល់ការជន្លៀសប្រជាពលរដ្ឋដែលបានកាន់កាប់ដីស្របច្បាប់ពីមុនទេ) ៤-ឯកសារបច្ចុប្បន្នភាពធានាសុវត្ថិភាពបរិស្ថាន (ជាឯកសារសម្រាប់តម្រង់ទិសដល់ការអនុវត្តគម្រោងដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋាន ក្នុងតំបន់គោលដៅរបស់គម្រោង LASED ទាំង១៣ឃុំ ដោយគិតគូដល់ផលប៉ះពាល់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ UXO និងបណ្តុះបណ្តាលលើការយល់ដឹងពីការការពារបរិស្ថាន) ៥-ឯកសារយុទ្ធសាស្ត្រនិរន្តរភាពគម្រោង (ការផ្តល់កម្មសិទ្ធិដីធ្លី គាំទ្រការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់អ្នកទទួលដី រៀបចំថែទាំសមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធ និងសង្វាក់ទីផ្សារផលិតកម្មកសិកម្ម។ ៦-ប៉ាន់ប្រមាណពីកម្មវិធីវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដោយ WB និងKfW (ជាតារាងប៉ាន់ស្មានពីថវិកាវិនិយោគដែលគាំទ្រដោយ World Bank និង KfW ទៅលើតំបន់គោលដៅទាំង១៤ ដែលក្នុងនោះKfWបានគ្រោងថវិកា៥លានដុល្លារអាមេរិក និង World Bank ចំនួន១០លានដុល្លារអាមេរិក) ៧-បញ្ចប់ការគ្រោងតម្លៃ និងកញ្ចប់ថវិការបស់គម្រោងបានរៀបចំគ្រោងថវិកាសរុបចំនួន ២៥លានដុល្លារអាមេរិក ដែលក្នុងនោះមានថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន ៣លានដុល្លារអាមេរិក និងថវិការបស់ធនាគារពិភពលោកចំនួន ២២លានដុល្លារអាមេរិក និង៨-ផែនការលទ្ធកម្ម (ជាឯកសារដែលរៀបរាប់អំពីកញ្ចប់ការងារលទ្ធកម្ម ស្របតាមនីតិវិធីលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចែកជា៣ប្រភេទគឺទំនិញ សំណង់ស៊ីវិល និងសេវាកម្ម)

២-ការងារថ្នាក់ខេត្ត

- ក្រុមការងារគម្រោង LASED ខេត្តកំពង់ចាម បានចុះប្រជុំផ្សព្វផ្សាយអំពីហានិភ័យគ្រោះមហន្តរាយ ពង្រឹងគណៈកម្មាការថែទាំ និងជួសជុលសមិទ្ធផលគម្រោងជម្រុញប្រជាពលរដ្ឋឲ្យសងបង្គន់អនាម័យ និងតាមដានដំណើរការអនុវត្តរបស់សហគមន៍អភិវឌ្ឍកសិកម្មដែលមានប្រជាពលរដ្ឋចូលរួមចំនួន៣៧នាក់ (ស្រីចំនួន

០៥នាក់) និងសហការជាមួយគណៈកម្មាការគ្រប់គ្រងសមិទ្ធផលគម្រោង បំផុសថៃទាំ និងជួសជុល ប្រជាពលរដ្ឋចូលរួមទិវាពលកម្មសំអាតនិងជួសជុលផ្លូវនៅក្នុងដីសម្បទានរៀងរាល់០២សប្តាហ៍ឬមួយខែម្តង។

- ក្រុមការងារគម្រោងខេត្តក្រចេះ បានចុះត្រួតពិនិត្យ និងធ្វើការវាយតំលៃការសាងសង់ប៉ុស្តិ៍សុខភាព ការបោះបង្គោលព្រំដីលំនៅដ្ឋាន និងកសិកម្ម ការជីកស្រះសហគមន៍ឃុំចំបក់ ការសាងសង់លូប្រអប់ក្នុងដីសម្បទានសង្គមកិច្ចឃុំសំបុក និងការបោះបង្គោលព្រំដីលំនៅដ្ឋាន និងកសិកម្មក្នុងដីសម្បទានសង្គមកិច្ចឃុំដារ។ ជាលទ្ធផលការងារសាងសង់ប៉ុស្តិ៍សុខភាព និងការបោះបង្គោលព្រំដីលំនៅដ្ឋាន និងកសិកម្ម ការជីកស្រះសហគមន៍ឃុំចំបក់សំរេចលទ្ធផលបាន១០០% ហើយ។ ចំពោះសាងសង់លូប្រអប់ក្នុងដីសម្បទានសង្គមកិច្ច ឃុំសំបុក និងការជីកស្រះសហគមន៍នៅឃុំចំបក់ ក្រុមការងារបានណែនាំឲ្យក្រុមហ៊ុនចាក់ដីបន្ថែមលើទីតាំងដាក់លូ និងបង្ហាប់ដីឲ្យបានស្អាត។ ដោយឡែកចំពោះការបោះបង្គោលព្រំដីលំនៅដ្ឋាន និងកសិកម្មក្នុងដីសម្បទានសង្គមកិច្ចឃុំដារ ក្រុមការងារគម្រោងបានរកឃើញថាក្រុមហ៊ុនបានដាំបង្គោលខុសទីតាំងចំនួន៤ដើម ហើយបានណែនាំក្រុមហ៊ុនឲ្យដាំបង្គោលទាំងនោះឲ្យចំទីតាំង។ ក្រៅពីនេះ ក្រុមការងារគម្រោងខេត្តក្រចេះសហការជាមួយគណៈកម្មការគ្រប់គ្រងសមិទ្ធផលគម្រោង បានសម្របសម្រួលលើកទឹកចិត្តប្រជាពលរដ្ឋនៅឃុំដារចំនួន ១២០នាក់(ស្រី១៥នាក់) ចូលរួមជួសជុលស្ពានឈើមួយកន្លែងបានប្រជុំពិភាក្សាជាមួយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរៀបចំ នីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅលើដីសម្បទានសង្គមកិច្ចឃុំសំបុក និងឃុំចង្រ្កង់ និងបានសម្របសម្រួលការងារជាមួយអង្គការ **Raw Impact** ធ្វើការបណ្តុះបណ្តាលអំពីការរៀបចំសួនបន្លែជាលក្ខណៈគ្រួសារ ដល់ប្រជាពលរដ្ឋនៅឃុំដារ ចំនួន ១២ នាក់ (ស្រី១០នាក់) ។
- ក្រុមការងារគម្រោង LASED ខេត្តកំពង់ធំ បានចូលរួមសម្របសម្រួលការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីសម្រាប់សហគមន៍ភូមិសែនអភិវឌ្ឍន៍២ ដែលមានប្រជាពលរដ្ឋចូលរួមសរុប ១១៦ នាក់ក្នុងនោះស្រី៥៤នាក់។ ជាលទ្ធផលជ្រើសរើសគណៈកម្មការសហគមន៍បានចំនួន០៧រូប ក្នុងនោះស្រីមានចំនួន០២រូប។ ក្រៅពីនេះ ក្រុមការងារគម្រោងក៏បានចុះផ្សព្វផ្សាយអនុក្រឹត្យស្តីពីការទទួលស្គាល់ភូមិថ្មី "ភូមិអូរធំ" ពង្រឹងប្រជាពលរដ្ឋអំពីការប្រើប្រាស់ដីកសិកម្ម ការតាមដានការងារអនុវត្តន៍កិច្ចសន្យា និងការរៀបចំផែនការដីសម្បទាននិងបញ្ចូលផែនការទាំងនោះទៅក្នុងផែនការ វិនិយោគឃុំដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន១២៦នាក់ក្នុងនោះស្រីមានចំនួន ៦៥នាក់ ។
- ក្រុមការងារគម្រោង LASED សហការជាមួយឃុំគោលដៅដីសម្បទានសង្គមកិច្ចបង្កើតគណៈកម្មការគ្រប់គ្រងសមិទ្ធផលគម្រោងបានចំនួន៥កន្លែង ដែលមានលោកមេឃុំជាប្រធានគណៈកម្មការ និងកំពុងរៀបចំដំណើរការផ្ទេរសមិទ្ធផលគម្រោងទៅជាកម្មសិទ្ធិឃុំ។

## II.ការចារបរិញ្ញវត្ថុ

ធនាគារពិភពលោកបានទំលាក់ថវិកាសរុបចំនួន ១០.៧២៨.២៧៨,០០ដុល្លារអាមេរិក ស្មើនឹង ១០០% នៃថវិកាសរុប(៧.០០០.០០០,០០ SDR) របស់គម្រោង។ ដោយឡែកធនាគារពិភពលោកបានទទួលស្គាល់លើថវិកាចំណាយជាក់ស្តែងគិតត្រឹមខែមិថុនា ឆ្នាំ២០១៤ ចំនួន ១០.៣៩៩.២៤៧,០០ ដុល្លារអាមេរិក (៦.៧៥២.៥៧៥ SDR) ដែលស្មើនឹង ៩៦,៤៧% នៃថវិកាគម្រោងសរុប។

## III. បញ្ហាប្រឈម និងសំណូមពរ

- ផលិតផលកសិកម្ម(ដំឡូងមី) ដែលគ្រួសារទទួលដីសម្បទានសង្គមកិច្ចខ្វះទីផ្សារ។
- ជំនន់ទឹកភ្លៀងបានធ្វើឲ្យប៉ះពាល់ដំណាំកសិកម្មរបស់ប្រជាពលរដ្ឋនៅលើដីសម្បទានសង្គមកិច្ចខេត្ត កំពង់ចាម។

## IV.ផែនការអនុវត្តបន្ត

- ត្រៀមពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលមានស្រាប់ និងរៀបចំបង្កើនសហគមន៍កសិកម្មនៅតំបន់ដីសម្បទានសង្គមកិច្ច។
- ក្រុមការងារគម្រោង LASED នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៃក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រៀមឯកសារ និងសុំគោលការណ៍ជាផ្លូវការដើម្បីអនុវត្តគម្រោងដំណាក់កាលទី២។
- ត្រៀមពង្រឹងការអនុវត្តគម្រោងបន្ត និងបញ្ចប់ការទូទាត់កិច្ចសន្យាលទ្ធកម្មដែលនៅសល់។

សក់_សេដ្ឋា

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**និងជា ប្រធានសម្របសម្រួលគម្រោងLASED**

ងាម ប៉េអា

ឡុង សុន

**ចំលងជូន**

-គ្រប់នាយកដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

-គ្រប់អង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប